រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៣

## សេចក្តីសំរេចលេខ ៤២ សសរ ស្តីពីគោលការណ៍គ្រប់គ្រងទត្តអារាម និង ទ្រព្យសម្បត្តិគរុភណ្ឌសង្ឃ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាអធិបតី ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

### សំរេច

**ប្រការ ១ :** ទ្រព្យគរុភណ្ឌ រួមមានដីធ្លីក្នុងបរិវេណវត្ត សំណង់ទាំងឡាយមាន កុដិ វិហារ សាលា ចេតិយ ប៉ាឆា និង ដំណាំដាំដុះដើមឈើជាដើម ត្រូវប្រគល់ទៅព្រះសង្ឃគ្រប់គ្រង ។

**ប្រការ ២ :** អង្គភាពរដ្ឋ និង ជនទាំងឡាយដែលបានសាងសង់អាគារធំតូចនៅលើដីវត្ត ដើម្បីធ្វើជាលំនៅដ្ឋានក្តី ធ្វើជាកន្លែងប្រកបរបរអាជីវកម្ម សេវាកម្ម ផលិតកម្ម ឬសិប្បកម្មក្តី ត្រូវរុះរើសំណង់ទាំងនោះចេញអោយផុតពីបរិវេណវត្ត ហើយប្រគល់ ដី ទីកន្លែង នោះអោយវត្តវិញ ។

**ប្រការ ៣ :** ជនទាំងឡាយ និង រដ្ឋអំណាចមូលដ្ឋាន ដែលបានយកសំណង់របស់វត្ត មានព្រះវិហារ កុដិ សាលាបុណ្យ សាលាឆាន់ ចេតិយ ទីប៉ាឆាជាដើម ដើម្បីធ្វើជាលំនៅស្ថានជាទីស្នាក់ការរដ្ឋបាល ឬ ប្រកបរបរដូចក្នុងប្រការ ២ ឬធ្វើជាកន្លែងប្រតិបត្តិផ្សព្វផ្សាយអបិយជំនឿផ្សេងៗ ផ្ទុយពីព្រះពុទ្ធសាសនាត្រូវចាកចេញអោយផុតពីសំណង់របស់វត្ត ហើយត្រូវប្រគល់អាគារគរុភណ្ឌទាំងនោះប្រគេនព្រះសង្ឃគ្រប់គ្រង វិញ ។

**ប្រការ ៤ :** គ្មានបុគ្គលណាឬក្រុមបុគ្គលណាមានសិទ្ធិទៅទន្ទ្រានកាន់កាប់ ឬ ប្រើប្រាស់ទ្រព្យគរុភណ្ឌ ដោយ

អនុញ្ញាតពីព្រះសង្ឃឡើយ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការ ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀង១ ខ្លួន ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពអនុវត្ត ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី ទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * * * *